**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យាព្រមព្រៀង
# រវាងសណ្ឋាគារ និងបុគ្គលិក/និយោជិត

**យោងតាម** ៖ លិខិតលេខ ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ស្ដីពីការព្យួរកិច្ចសន្យា

**កម្មវត្ថុ** ៖ សំណើសុំព្យួរកិច្ចសន្យាការងារ បុគ្គលិក/និយោជិតចំនួន ៤៧នាក់ រយៈពេល ២ខែ

សេចក្ដីដូចបានចែងទុកក្នុងកម្មវត្ថុ និងយោងខាងលើ និងឆ្លើយតបតាមប្រសាសន៍លោកនាយកគ្រប់គ្រងតំណាងក្រុមហ៊ុនបានផ្ដល់ព័ត៌មានបំភ្លឺយ៉ាងក្បោះក្បាយដូចខាងក្រោម៖ បច្ចុប្បន្ន **សណ្ឋាគារ អេ នីក** អនុវត្តសម្រេចសុំព្យួរកិច្ចសន្យាការងារបុគ្គលិក/និយោជិតទាំងអស់ចំនួន ៤៧នាក់ ប្រុស ២៨នាក់ ស្រី ១៩នាក់ ជាបណ្ដោះអាសន្នដោយគិតចាប់ពីថ្ងៃ០១ ខែឧសភា ហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

ក្នុងរយៈពេលនៃការធ្វើកិច្ចព្រមព្រៀងរវាងបុគ្គលិក/និយោជិត ក្រុមហ៊ុនមិនបានផ្ដល់ប្រាក់បៀវត្សរ៍ជូនបុគ្គលិក/និយោជិតឡើយ ក្នុងនោះរាជរដ្ឋាភិបាលនិងផ្ដល់ប្រាក់ឧបត្ថម្ភបន្ថែមចំនួន ៤០ដុល្លាអាមេរិច ក្នុងមួយខែសម្រាប់បុគ្គលិកនិយោជិតគ្រប់រូប។ ដើម្បីទទួលប្រាក់ឧបត្ថម្ភបន្ថែមនេះលុះត្រាបុគ្គលិក/និយោជិតត្រូវផ្ដល់លេខបណ្ណសមាជិក ប.ស.ស និងលេខអត្តសញ្ញាណប័ណ្ណ, លេខទូរស័ព្ទអោយបានច្បាស់លាស់ពិតប្រាកដ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ..២៨.. ខែ..មេសា.. ឆ្នាំ២០២០

អ្នកតំណាងបុគ្គលិក/និយោជិត

អ្នកតំណាងសណ្ឋាគារ

ហត្ថលេខា និងត្រា
**គណៈនាយកគ្រប់គ្រងសណ្ឋាគារ**
**(អេ នីក ហូថេល ឯ.ក)**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
អេ នីក ហូថេល ឯ.ក
A NIK HOTEL CO., LTD.
KINGDOM OF CAMBODIA

**លោក ធូច សុផាត**

Head Office: No. 158, Norodom Blvt., Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh, Kingdom of Cambodia
Tel: +855 23 955 544 / 23 955 545 / 012 952 456 / 016 882 487
E-mail: info@anikhotelgroup.com / Website: www.anikhotelgroup.com